Alameda County Health

## សម្រាប់ប្រកាសព័ត៌មានបន្ទាន់

ថ្ងៃទី 27 ខែមីនា ឆ្នាំ 2024

ទំនាក់ទំនងមេខា៖
ACHealth-PIO@acgov.org

# ស្វាគមន៍មកកាន់ Alameda County Health

## ទីភ្នាក់ងារសេវាកម្មថែទាំសុខភាពសូមណែនាំពីឈ្មោះ និងរូបរាងថ្មី

**Alameda County, CA -** នៅថ្ងៃនេះ ទីភ្នាក់ងារសេវាកម្មថែទាំសុខភាពនៃខោនធី Alameda (Alameda Country Health Care Services Agency) បានប្រកាសអំពីអត្តសញ្ញាណថ្មីរបស់ខ្លួនជា Alameda County Health (AC Health)។ ដោយមានទីស្នាក់ការនៅ San Leandro និងបម្រើសេវាកម្មជូនប្រជាពលរដ្ឋជាង 1.7 លាននាក់ នៅក្នុងខោនធីចម្រុះបំផុតនៅក្នុងប្រទេស គឺ AC Health នៅតែចាក់ឫសលើសមភាពសុខភាព និងការថែទាំសម្រាប់ប្រជាពលរដ្ឋទាំងមូល។

ជាមួយនឹងនាយកដ្ឋាន និងកម្មវិធីអន្តរទីភ្នាក់ងារជាច្រើន និងដោយសហការជាមួយនឹងអង្គការសហគមន៍ចំនួនច្រើនជាង 300 អង្គការ AC Health បន្តផ្តល់សេវាកម្មសំខាន់ៗជូនពលរដ្ឋក្នុងខោនធី Alameda ក្នុងនោះ រួមមាន សុខភាពសាធារណៈ សុខភាពឥរិយាបថ សុខភាពបរិដ្ឋាន EMS សេវាកម្មលំនៅឋាន និងភាពគ្មានផ្ទះសម្បែង និងកម្មវិធីជាច្រើន ដែលលើកកម្ពស់លទ្ធភាពទទួលបានការថែទាំ និងជួយលុបបំបាត់អសមភាពនៃសុខភាព។

កិច្ចខំប្រឹងប្រែងផ្សព្វផ្សាយអត្តសញ្ញាណថ្មីនេះ ត្រូវបានជម្រុញមួយផ្នែក ដោយសារបទពិសោធន៍ដែលបានរៀនសូត្រពីវិបត្តិជំងឺឆ្លងជាសាកល នៅពេលដែលព័ត៌មានអាចទទួលបាន ច្បាស់លាស់ និងអាចយល់បានពិតជាមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋ ដែលស្វែងរកសេវាកម្មគាំពារសំខាន់ៗ និងសេចក្តីណែនាំអំពីសុខភាព និងព័ត៌មានវេជ្ជសាស្ត្រ ដែលអាចទុកចិត្តបាន។

Keith Carson ប្រធានគណៈកម្មាធិការសុខាភិបាល និងអ្នកត្រួតពិនិត្យ District 5 នៃខោនធី Alameda បានថ្លែងថា៖ "AC Health ដើរតួនាទីសំខាន់ ក្នុងការជួយ និងការពារសុខភាពរបស់ប្រជាពលរដ្ឋនៅក្នុងខោនធី Alameda ហើយនេះគឺអំពីការធានាថា ប្រជាពលរដ្ឋរបស់យើងយល់ដឹងច្បាស់អំពីទីកន្លែងដែលត្រូវទៅ ដើម្បីទទួលបានសេវាកម្ម និងធនធានដែលអាចសង្គ្រោះជីវិតរបស់ពួកគេ"។ "អត្តសញ្ញាណថ្មីនឹងធ្វើឲ្យកាន់តែងាយស្រួលក្នុងការចែករំលែកព័ត៌មាន និងសារជូនសហគមន៍របស់យើង ហើយទីបំផុត នឹងធ្វើឲ្យប្រជាពលរដ្ឋកាន់តែងាយយល់ដឹងពីសេវាកម្ម និងធនធានទាំងអស់ ដែលខោនធីផ្តល់តាមរយៈ AC Health"។

អត្តសញ្ញាណថ្មីរបស់ទីភ្នាក់ងារ ត្រូវបានបង្កើតឡើង ដោយមានមតិ និងយោបល់ពីបុគ្គលិក និងដៃគូសហគមន៍ ដើម្បីសម្រួលដល់ការបង្កើតអត្តសញ្ញាណមួយ ដែលឆ្លុះបញ្ចាំងពីសេវាកម្មទូលំទូលាយ ដែលជួយដល់សហគមន៍ និងសេចក្តីត្រូវការចម្រុះនៅក្នុងខោនធី Alameda។ AC Health នឹងចាប់ប្រើសារទំនាក់ទំនង ស្លាកសញ្ញាអគារ និងឯកសារផ្លូវការក្នុងអំឡុងឆ្នាំក្រោយ។ គេហទំព័រថ្មីនឹងដាក់ឲ្យដំណើរការក្នុងរដូវក្តៅនេះ ជាមួយគោលដៅចម្បងគឺដើម្បីធ្វើឲ្យកាន់តែងាយស្រួលក្នុងការស្វែងរកព័ត៌មានពីចំណុចចូល/ស្វែងរកច្រើនកន្លែង និងដើម្បីពង្រឹងលទ្ធភាពចូលប្រើប្រាស់សម្រាប់មនុស្សដែលចុះខ្សោយចក្ខុញ្ញាណ និងអ្នកដែលនិយាយភាសាផ្សេង។

Colleen Chawla ប្រធានទីភ្នាក់ងារសេវាកម្មថែទាំសុខភាពរបស់ខោនធី បានថ្លែងថា៖ "ខណៈដែលឈ្មោះ និងរូបសញ្ញារបស់យើងកំពុងតែផ្លាស់ប្តូរ ក៏ប៉ុន្តែរចនាសម្ព័ន្ធ និងចំណុចខ្លាំងរបស់ទីភ្នាក់ងាររបស់យើង និងការប្តេជ្ញារបស់យើងចំពោះមនុស្សគ្រប់រូប ដែលយើងបម្រើ

Alameda County Health

សេវាកម្ម គឺនៅតែរក្សាដដែល”។ “មានការសម្របសម្រួលជាច្រើនក្នុងនាយកដ្ឋាន និងកម្មវិធីជាច្រើនរបស់យើង ដើម្បីផ្តល់សេវាកម្មគុណភាពខ្ពស់ និងបង្កើនលទ្ធផលសុខភាពជូនប្រជាពលរដ្ឋខោនធី Alameda - អត្តសញ្ញាណថ្មីនេះនឹងជួយគូសបញ្ជាក់ពីទំនាក់ទំនងទាំងនោះឲ្យកាន់តែច្បាស់លាស់ និងសម្រាប់អតិថិជន និងសហគមន៍របស់យើង”។

ខណៈដែលបេសកកម្ម ចក្ខុវិស័យ និងរចនាសម្ព័ន្ធស្ថាប័នរបស់ទីភ្នាក់ងារ និងនាយកដ្ឋានរបស់ទីភ្នាក់ងារនឹងរក្សានៅដដែល ការផ្លាស់ប្តូរឈ្មោះខាងក្រោមនឹងត្រូវអនុវត្ត ចាប់ពីថ្ងៃទី 27 ខែមីនា ឆ្នាំ 2024 តទៅ៖

- **Alameda County Health (AC Health)**
  ពីមុនគឺ៖ Alameda County Health Care Services Agency ឬ HCSA
- **AC Health, Behavioral Health Department (ACBHD)**
  ពីមុនគឺ៖ Alameda County Behavioral Health Care Services ឬ ACBH
- **AC Health, Environmental Health Department (ACEHD)**
  ពីមុនគឺ៖ Alameda County Department of Environmental Health ឬ DEH
- **AC Health Public Health Department (ACPHD)**
  ពីមុនគឺ៖ Alameda County Public Health Department ឬ ACPHD
- **AC Health, Housing and Homelessness Services (AC Health H&H)**
  ពីមុនគឺ៖ Office of Homeless Care and Coordination ឬ OHCC
- **AC Health, Healthy Schools and Communities**
  ពីមុនគឺ៖ The Center for Healthy Schools and Communities

**Alameda County EMS Agency និង HealthPAC** នឹងរក្សាឈ្មោះបច្ចុប្បន្នរបស់ពួកគេ។

សម្រាប់ព័ត៌មានបន្ថែមអំពីទីភ្នាក់ងាររបស់យើង សូមចូលទៅ Health.AlamedaCountyCA.gov

សេចក្តីប្រកាសព័ត៌មានជា៖ភាសាអេស្ប៉ាញ | ភាសាចិន | ភាសា Farsi | ភាសាវៀតណាម | ភាសាខ្មែរ | ភាសា Tagalog

###

## អំពី Alameda County Health

ទីភ្នាក់ងារសេវាកម្មថែទាំសុខភាពខោនធី Alameda (Alameda County Health Care Services Agency) គឺជាទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន ដែលលើកកម្ពស់ និងការពារសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅ ធ្វើការ រៀនសូត្រ និងលេងកីឡានៅក្នុងខោនធី Alameda។ ជាមួយនឹងនាយកដ្ឋានសុខភាពបរិដ្ឋាន សុខភាពឥរិយាបថ និងសុខភាពសាធារណៈ និងកម្មវិធីចម្បងៗដែលផ្តោតលើការឆ្លើយតបនៅក្នុងគ្រាអាសន្ន លទ្ធភាពទទួលបានការថែទាំ និងសេវាកម្មសម្រាប់ភាពគ្មានផ្ទះសម្បែង យើងសម្របសម្រួល និងចាប់ដៃគូជាមួយអង្គការសហគមន៍ ដើម្បីជួយបង្កើតប្រព័ន្ធសុវត្ថិភាពដ៏រឹងមាំ សហគមន៍ឆាប់រើបឡើងវិញ និងលើកកម្ពស់សុខភាពសម្រាប់មនុស្សគ្រប់រូប។ យើង

Alameda County Health

ផ្តោតលើសមភាពនៃសុខភាព តាមរយៈកម្មវិធី និងការផ្លាស់ប្តូរជាលក្ខណៈប្រព័ន្ធ ដើម្បីកាត់បន្ថយអសមភាពជូនប្រជាពលរដ្ឋ និងសហគមន៍ ដែលយើងបម្រើសេវាកម្ម។